**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៨១.០១៩.០៦១ ៧សស

# លិខិតអបអរសាទរ

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

តាងនាមថ្នាក់ដឹកនាំមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជានិងរូបខ្ញុំផ្ទាល់ ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយជាអនេក និងអំណរសាទរយ៉ាងក្លៀវក្លាជាទីបំផុត នៅក្នុងឱកាសដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ត្រូវបាន អង្គការសហព័ន្ធសន្តិភាពសកល (UPF) ប្រគល់ពានរង្វាន់ "ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ" នៅថ្ងៃអង្គារ ៨រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

ការប្រគល់ពានរង្វាន់ "ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ" ជូនសម្តេចតេជោនាយករដ្ឋមន្ត្រី គឺជាមោទនភាពជាតិដ៏ធំធេងថ្មីមួយទៀត និងពិតជាបានឆ្លើយតបយ៉ាងស័ក្តិសមបំផុតចំពោះវីរភាព សមត្ថភាព និងស្នាដៃដ៏ឧត្តុង្គឧត្តមដែល សម្តេចតេជោនាយករដ្ឋមន្ត្រី បានខិតខំប្រឹងប្រែងលះបង់ អស់កម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតី ក្នុងការស្វែងរកសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ ឯកភាពជាតិ ជូនប្រជាជន និងជាតិមាតុភូមិ ក្រោមនយោបាយឈ្នះ-ឈ្នះរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី និងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់លើគ្រប់វិស័យប្រកបដោយចីរភាព បរិយាប័ន្ន និងមានចក្ខុវិស័យវែងឆ្ងាយ។ ពានរង្វាន់នេះ ក៏ជាសក្ខីភាពនៃភាពដ៏ប៉ិនប្រសប់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងការបង្កើតទំនាក់ទំនងការទូត និងការពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសជាមិត្តក្នុងតំបន់ នឹងលើពិភពលោក ដែលធ្វើឱ្យកម្ពុជាមានកិត្យានុភាពល្បីរន្ទឺលើឆាកអន្តរជាតិ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ទេវតា និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមមេត្តាជួយថែរក្សា ការពារ និងប្រសិទ្ធពរជ័យ បវរសួស្តី មហាប្រសើរ ជូនចំពោះ សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រី សូមបានប្រកបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីបន្តបេសកកម្មដ៏ថ្លៃថ្លា ដឹកនាំព្រះរាជាណាចក្រកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍ និងសម្បូររុងរឿង តរៀងទៅ។

សូម សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងដោយស្មោះស្ម័គ្របំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ពុធ ៩រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៩
**តំណាងមន្ត្រីបុគ្គលិក ធនាគារជាតិនៃកម្ពុជា**
**ទេសាភិបាល**

ជា-ចាន់តូ